00338313

Declassified to Public
06 September 2012

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 10 / JUN / 2009
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. [signature]



## ទម្រង់ព័ត៌មានជនរងគ្រោះ

ជាបឋមខ្ញុំសូមបញ្ជាក់ជូនថា ខ្ញុំគឺជាអ្នកស្នេហាសន្តិភាពនិយម។ ខ្ញុំគ្មានបំណងសងសឹកអ្វីទេ។ ប៉ុន្តែតាមពិតមនុស្ស និងប្រជាជាតិភាគច្រើន ចង់បានការទទួលខុសត្រូវមួយ ប្រសិនបើពួកគេ ឬមនុស្សជាទីស្រលាញ់ពួកគេ រងនូវការឈឺចាប់។ កិច្ចដំណើរការនេះមានសារៈសំខាន់ណាស់សម្រាប់បុគ្គលទាំងឡាយ ដើម្បីចាប់ផ្តើមដំណើរការជាសះស្បើយ និងសម្រាប់ប្រទេសដែលរងនូវការខ្ទេចខ្ទាំ ចាប់ផ្តើមកសាងប្រជាជាតិឲ្យមានសុខភាពល្អឡើងវិញ។

## ផ្នែក ខ

### ការពិពណ៌នាអំពីបទឧក្រិដ្ឋទាំងឡាយ (ផ្នែក ខ សំណួរ១)

១.១ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៨ នាវាកំសាន្តប្រវែង២៨ហ្វុតមួយគ្រឿងឈ្មោះ Foxy Lady បានបោះយុថ្កា ហើយជ្រកកោននៅក្នុងឈូងសមុទ្រនៃកោះ Koh Tang។ ម្ចាស់នាវានោះគឺជា បងប្រុសរបស់ខ្ញុំឈ្មោះ Kerry George Hamil។ ឯម្ចាស់នាវម្នាក់ទៀតឈ្មោះ Stuart Glass ជាជន ជាតិកាណាដា។ មនុស្សទីបីនៅលើនាវាគឺជាអ្នកធ្វើដំណើរបង់ប្រាក់ ជនជាតិអង់គ្លេស ឈ្មោះ John Dewhurst។

១.២ នៅល្ងាចនោះ ដោយគ្មានការការដឹងមុន គ្រាប់កាំភ្លើងត្រូវបានគេបាញ់ទៅលើនាវា Foxy Lady ហើយនិងក្រុមយាវិក។ Stuart Glass ដែលឋិតនៅលើដំបូលនាវា ត្រូវបានគេបាញ់ត្រូវ។ Kerry ដែលឋិតនៅលើដំបូងនាវានោះដែរ បានយក Stuart ចូលទៅក្នុងទូកសង្គ្រោះ។

១.៣ John Dewhurst ដែលនៅពីក្រោមដំបូលនាវាពេលបាញ់ គាត់បានដើបឡើងពីខាងក្រោម ហើយជ្រកជាមួយនឹង Kerry ដោយឡើងទូកនៅលើទឹក។

១.៤ នាវាប្រដាប់ដោយអាវុធ បានមកយកបុរសពីរនាក់ទៅ។

១.៥ Stuart Glass បានស្លាប់ ហើយកប់នៅឯសមុទ្រ។

១.៦ ដូចបានលើកឡើងនៅក្នុងរបាយការណ៍កងពលធំលេខ១៦៤ មាស មុត ជាអ្នកទទួលបន្ទុកខ្ពស់បំផុតនៅលើនាវាប្រដាប់ដោយអាវុធរបស់ខ្មែរក្រហម ដែលបានចាប់បុរសស្លូតត្រង់ពីរនាក់ នោះហើយបានសម្លាប់ Stuart Glass។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

១.៧ បុរសទាំងនោះត្រូវគេដាក់ខ្នោះ ហើយចងមុខ បន្ទាប់មកនាំខ្លួនទៅកាន់រោងភាពយន្តនៅក្រុងព្រះសីហនុ ជាកន្លែងដែលពួកគេត្រូវបានគេឃុំខ្លួន មុនពេលយកមកកាន់គុកទួលស្លែង (ស-២១) ក្នុងទីក្រុងភ្នំពេញ។

១.៨ នៅគុកទួលស្លែង បុរសទាំងពីរនាក់នោះ ត្រូវទទួលការសួរចម្លើយ និងធ្វើទារុណកម្មដោយការឆក់នឹងដំបងឆក់ ប្រហែលជានៅក្នុងដៃរបស់ប្រធានសួរចម្លើយ សមមិត្តចាន់។ ជាយថា ហេតុបុរសទាំងពីរនាក់នោះ ត្រូវបានគេបង្ខំឱ្យចុះហត្ថលេខាលើចម្លើយសារភាព ដោយនិយាយថា ខ្លួន ជាភ្នាក់ងារCIA។

១.៩ ក្នុងចម្លើយប្រឌិតរបស់គាត់ Kerry បាននិយាយថា វរៈសេនីយ៍ឯក Sanders (នៃ Kentucky Fried Chicken Fame)គឺជាចៅហ្វាយម្នាក់ក្នុងចំណោមចៅហ្វាយរបស់ខ្លួន។ គាត់បានប្រើលេខទូរស័ព្ទនៅផ្ទះ(៨៧០៨)ជាលេខប្រតិបត្តិការCIA របស់គាត់ ហើយបានពោលដល់មិត្តគ្រួសារមួយចំនួនជាសមាជិកCIA ជួយបណ្តុះបណ្តាលគាត់ក្នុងការស៊ើបការណ៍CIA។ល។

១.១០ ប្រហែលបីសប្តាហ៍បន្ទាប់ពីការចាប់ខ្លួនគាត់ John Dewhurst បានចុះហត្ថលេខាលើចម្លើយសារភាពមួយ ហើយត្រូវបានគេសម្លាប់។

១.១១ ប្រហែលពីរខែបន្ទាប់ពីការចាប់ខ្លួនគាត់ បងប្រុសខ្ញុំ Kerry Hamill បានចុះហត្ថលេខាលើចម្លើយសារភាពមួយ ហើយត្រូវបានគេសម្លាប់។

១.១២ វាជាការជាក់ស្តែងពីចម្លើយសារភាពទាំងពីរ ដែលពួកគេត្រូវបានគេទទួលក្រោមការធ្វើទារុណកម្ម។ បុរសទាំងនោះបានប្រឌិតរឿងថា ពួកគេបានទទួល "ការបណ្តុះបណ្តាលCIA" ទៅជា រឿងពិតអំពីជីវិតរបស់ពួកគេ។ ការប្រកាសរបស់ពួកគេថាបានទទួលការបណ្តុះបណ្តាលCIA គឺជាការមិនពិតយ៉ាងជាក់ស្តែង ហើយអាចត្រូវបដិសេធជាការស្រេច។

១.១៣ វិធីពិតប្រាកដនៃការសម្លាប់Kerryគឺមិនដឹងច្បាស់ទេ ប៉ុន្តែអាចនិយាយបានថា បងប្រុសរបស់ខ្ញុំ ត្រូវបានគេចងមុខ នាំចេញពីបរិវេណមន្ទីរស-២១ ទៅកាន់លេណដ្ឋានដែលបានជីករួច ឱ្យលត់ជង្គុងចុះក្បែរលេណដ្ឋាននោះ ហើយវាយទៅលើក្បាលជាមួយនឹងរបាដែកមួយបំពង់ករបស់ គាត់ត្រូវកាត់ បន្ទាប់មកគេកប់។ ថាតើនោះគាត់មានសំណាងទេ!

១.១៤ មានដំណើររឿងជនបរទេសពីរនាក់ ត្រូវបានគេដាក់ក្នុងសំបកកង់ឡាន ហើយបន្ទាប់មកចាក់សាំងពីលើ ហើយដុត។

១.១៥ តាមការប៉ាន់ស្មានរបស់លោក ជុង មី (Chung Mey) ក្នុងកិច្ចសម្ភាសន៍មួយ យើងសន្និដ្ឋានថា ហ៊ឹម ហុយ (Him Huy) និងសមមិត្ត ស្វ (Soer) ដើរតួនាទីក្នុងការសម្លាប់ទាំងនេះ។

**តើអ្នកណាជាអ្នកទទួលខុសត្រូវ? (ផ្នែក ខ សំណួរ២)**

២.១ ចំពោះការស្លាប់បងប្រុសខ្ញុំ ខ្ញុំចាត់ទុក កាំង ហ្កេក អ៊ាវ (ហៅ ឌុច)អ្នកត្រួតបញ្ជាមន្ទីរ ស-២១ ជាអ្នកទទួលខុសត្រូវដោយផ្ទាល់។ គាត់គឺជាអ្នកមើលការខុសត្រូវការធ្វើទារុណកម្មKerry ហើយគាត់ក៏ជាមនុស្សម្នាក់ ដែលចេញបញ្ជាឲ្យគេសម្លាប់បងប្រុសខ្ញុំដែរ។ ដោយមិនគិតអំពីការឆ្លើយដាក់នោះទេ។ គាត់ក៏មានអំណាចដោះលែង Kerry ផងដែរ អំណាចដែលគាត់មិនបានប្រើប្រាស់។

២.២ ទោះបីខ្ញុំឃើញ កាំង ហ្កេក អ៊ាវ ជាអាជ្ញាធរផ្ទាល់ទទួលខុសត្រូវចំពោះការសម្លាប់បងប្រុសខ្ញុំក៏ដោយ ក៏ការទទួលខុសត្រូវចុងក្រោយធ្លាក់ទៅលើអ្នកដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមដែរ។ អ្នកដែលកាន់អំណាចនៅពេលដែលគេនៅក្នុងគណៈរដ្ឋមន្ត្រី (ប្រឌិតពាក្យពេជប្រជាធិបតេយ្យលោកខាងលិច) គួរទទួលខុសត្រូវចំពោះព្រឹត្តិការណ៍សោកនាដកម្មដែលបានកើតឡើងនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ក្នុងប្រទេសកម្ពុជា។

២.៣ ពួកគេបានប្រព្រឹត្តិដូចគ្នានឹងពួកបីសាចប្រល័យពូជសាសន៍ ក្នុងរបៀបមួយដូចគ្នានឹង Adolf Hitler ក្នុងអំឡុងពេលសង្គ្រាមលោកទីពីរ។

២.៤ មើលទៅហាក់ដូចជាមនុស្សតែម្នាក់(ឈ្មោះ ប៉ុល ពត)ឲ្យបង្កើតជា "ក្រុម" បងធំ វាដូចជា វាដូចជាការយកតែមនុស្សម្នាក់មកទទួលខុសត្រូវអញ្ចឹង។

២.៥ ខ្ញុំជឿជាក់ថា អ្នកណាម្នាក់ក្នុងចំណោមមេដឹកនាំទាំងនោះ អាចបានប្រើឥទ្ធិពលលើអ្នកផ្សេងទៀត (ដោយប្រើកលល្បិច និងដោយការទុកចិត្តសមស្រប) ហើយអាចបានផ្លាស់ប្តូរទិសដៅនៃប្រវត្តិសាស្ត្រ។ អាយុជីវិតមនុស្សប្រហែលរាប់ម៉ឺននាក់ អាចត្រូវបានគេសង្គ្រោះ រួមទាំងជីវិតបងប្រុសខ្ញុំ និងមិត្តភ័ក្តិខ្ញុំផងដែរ។

២.៦ ឯកសារប្រវត្តិសាស្ត្របញ្ជាក់ច្បាស់ថា មេដឹកនាំមួយចំនួនមានមានការសង្ស័យ ប៉ុន្តែគ្មានអ្នកណាម្នាក់សុខចិត្តធ្វើការលំបាក ហើយធ្វើការងារនោះឲ្យបានត្រឹមត្រូវទេ។ ប្រៀបបីដូចជាស្ទឹងមួយ ពួកគេជ្រើសយកផ្លូវមួយដែលមានការតស៊ូតិចតួច។ ពួកគេមានការអាម៉ាស់មុខ។ ពួកគេអាម៉ាស់គ្រប់យ៉ាងចំពោះអ្វី ដែលជាភាពគ្មានសេចក្តីក្លាហានរបស់ពួកគេ ជាអំពើឃោរឃៅដ៏កំសាក។

២.៧ គេស្គាល់ឈ្មោះអ្នកដឹកនាំ ឬ "បងធំ"ទាំងនោះ មានឈ្មោះដូចខាងក្រោម៖

១. ប៉ុល ពត (ស្លាប់)

២. នួន ជា

៣. អៀង សារី

៤. ខៀវ សំផន

៥. តា ម៉ុក (ស្លាប់)

៦. អៀង ធិរិទ្ធិ

៧. សុន សេន (ស្លាប់)

៨. យុន យ៉ាត (ស្លាប់)

៩. កែ ពក (ស្លាប់)

២.៨ ទោះយ៉ាងណា អ្នកទាំងឡាយណាដែលដើរតាមនិងអនុវត្តបទបញ្ជា និងប្រព្រឹត្តអំពើហិង្សាបែបនេះក៏ត្រូវយកមកគិតផងដែរ។ អ្នកខ្លះអាចត្រូវបានគេគំរាមកំហែង ប្រសិនបើពួកគេមិនគោរពតាម។ ប៉ុន្តែភាគច្រើនពួកគេអាចបានស្តាប់តាមមនសិកាជាមូលដ្ឋានរបស់ខ្លួន និងសិក្ខាបទនៃព្រះពុទ្ធសាសនា ហើយជំទាស់នឹងបទបញ្ជាប្រល័យពូជសាសន៍។

២.៩ នៅពេលណាបុគ្គលទាំងឡាយមានឆន្ទៈសម្លាប់រង្គាល ឆន្ទៈនោះអាចបញ្ចេញឥទ្ធិពលយ៉ាងធំធេង ប្រសិនបើបុគ្គលទាំងនោះបានជ្រើសរើស។

២.១០ ប្រព័ន្ធគ្រប់គ្រងដ៏ឃោរឃៅមួយបែបនេះជានិច្ចកាលតែងតែគ្មានស្ថេរភាពឡើយ តែងតែមានឱកាសមួយរៀបចំការប្រឆាំងតបតវិញ ហើយជនស៊ីវិលនៅថ្នាក់ក្រោមមិនស្តាប់បង្គាប់ទេ។ សមាជិកទាំងឡាយរបស់អ្នកដឹកនាំខ្មែរ មិនអាចឆក់យកឱកាសនោះបានទេ។

**ផ្នែក គ - ពាក្យសុំចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី**

**១. ខ្ញុំចង់ឲ្យគេជំនុំជម្រះក្នុងកិច្ចដំណើរការក្នុងសំណុំរឿងលេខ១**

**២. របួសស្នាម ការបាត់បង់ ឬគ្រោះថ្នាក់**

២.១ Kerry Hamil គឺជាកូនច្បងក្នុងចំណោមកូនទាំងប្រាំ ក្នុងគ្រួសាររបស់យើង រួមមាន John, Peter, Sue និងកូនពៅ Robert(ខ្ញុំ)។

២.២ ក្នុងឆ្នាំ១៩៧៨ ជាឆ្នាំដែលKerry ត្រូវបានគេសម្លាប់ នៅឯផ្ទះនេះវិញនៅWhakatane New Zealand យើងគ្មានយោបល់ចំពោះអ្វីដែលបានកើតឡើងនោះទេ។ អស់រយៈពេលជាច្រើន សប្តាហ៍កន្លងផុតដោយគ្មានទំនាក់ទំនងពីKerry។ ជាច្រើនសប្តាហ៍ទៅជាច្រើនខែនៅតែគ្មានទំនាក់ទំនង ពីKerry ដែលជាអ្នកធ្លាប់សរសេរសំបុត្រញឹកញាប់។

២.៣ ផ្ទះនៃក្រុមគ្រួសាររបស់យើងមានទីតាំងនៅមាត់ស្ទឹងWhakatane។ នៅចុងឆ្នាំម្តាយខ្ញុំឈ្មោះEsther Hamill សំឡឹងមើលឯនាយសមុទ្រ ហើយនិយាយរកអ្នកណាក៏ដោយដែលនៅក្បែរថា “មិនអីទេ គាត់នឹងបង្ហាញខ្លួនក្នុងពេលបុណ្យគ្រីស្ត ដើម្បីធ្វើឲ្យយើងភ្ញាក់ផ្អើល”។ យើងសង្ឃឹមពាក់កណ្តាលថា នាវានោះនឹងលេចខ្លួននៅឯជើងមេឃក្នុងពេលណាមួយ។ នៅក្នុងគ្រួសារយើងមាន អារម្មណ៍អស់សង្ឃឹម។

២.៤ បុណ្យគ្រីស្តឆ្នាំ១៩៧៨ មកដល់ ហើយប្រព្រឹត្តទៅដូចឆ្នាំមុនៗដែរ ហើយនៅតែគ្មានដំណឹងទៀត។

២.៥ ខណៈដែលពេលវេលាកន្លងផុតទៅ ឪពុកម្តាយខ្ញុំកាន់តែមានអារម្មណ៍អន្ទះសា។ យើងនៅតែសង្ឃឹមលើលទ្ធផលជាវិជ្ជមាន ប៉ុន្តែកាន់តែជ្រៅទៅយើងទាំងអស់គ្នាកំពុងគិតរឿងរ៉ាវអាក្រក់ ដដែលៗកើតឡើងចំពោះបងប្រុសខ្ញុំ។

២.៦ ឪពុកខ្ញុំឈ្មោះ Miles Hamill បានសរសេរលិខិតជាច្រើនទៅកាន់កំពង់ផែនានានៅសិង្ហបូរី ម៉ាឡេស៊ី និងថៃឡង់ ស្នើសុំព័ត៌មានទាក់ទងនឹងទីកន្លែងប្រហាក់ប្រហែលនៃនាវា Foxy Lady និងលទ្ធភាពនៃការឃើញនាវានោះ។ គាត់ក៏បានសរសេរលិខិតទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសផងដែរ ព្យាយាមដើម្បីធ្វើទិទស្សន៍ថាតើកម្មេចបាក់បែកនាវាណាមួយ ត្រូវបានគេរាយការណ៍នៅក្នុងតំបន់ ឬថាតើអ្វីមួយកើតឡើងខុសប្រក្រតី ដែលអាចមានសារៈសំខាន់។

២.៧ អស់រយៈពេលជិតមួយឆ្នាំបន្ទាប់ពីការចាប់ខ្លួនKerry មានដំណឹងលេចឮមកថា Kerry ត្រូវបានគេចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់ដោយដៃនៃរបបខ្មែរក្រហមប៉ុល ពត។

២.៨ យើងបានដឹងអំពីជោគវាសនាបងប្រុសខ្ញុំតាមរយៈដំណឹងនៅតាមវិទ្យុ និងអានកាសែត។ គ្មានអ្នកម្នាក់នៅក្នុងរដ្ឋាភិបាលNew Zealand ចំណាយពេលទាក់ទងឪពុកម្តាយខ្ញុំជាមួយនឹងដំណឹងនេះទេ។

២.៩ ខ្ញុំចាំបានថាខ្ញុំដឹងរឿងនេះលើកទីមួយពីការអានទំព័រមុខនៃសារព័ត៌មានក្នុងស្រុកមួយ។ អ្នកជិតខាងម្នាក់បានទូរស័ព្ទប្រាប់យើងឲ្យទៅទិញកាសែតនោះមួយច្បាប់។

២.១០ យើងទទួលរងការហិនហោចអស់។

២.១១ ខ្ញុំចាំបាននូវការឈរនៅក្នុងផ្ទះបាយអោបឪពុករបស់ខ្ញុំ យើងទាំងពីរនាក់នាំគ្នាយំចំពោះអ្វីដែលវាហាក់ដូចជាមានរយៈពេលយូរលង់មកហើយ។

២.១២ ដោយអវត្តមានរូបរបស់លោកKerry គេបានប្រារព្ធធ្វើពិធីរំឭកវិញ្ញាណក្ខន្ធ។

២.១៣ ឯកសារផ្លូវការមកពីInterpol ជាយថាហេតុ ជាមួយនឹងចម្លើយសារភាពរបស់Kerry បញ្ជាក់អំពីអ្វី ដែលបានកើតឡើង។

២.១៤ ឆ្នាំកន្លងទៅប្រកបដោយការរងចាំនៃនិងក្តីសង្ឃឹមគឺជាពេលវេលាដែលគួរឱ្យខ្លាចបំផុតសម្រាប់គ្រួសាររបស់យើង។ យើងគួរតែបានដឹងអ្វី ដែលបានកើតឡើងនៅពេលគេសម្លាប់Kerry។

២.១៥ ឆ្នាំជាបន្តបន្ទាប់កាន់តែអាក្រក់ទៅ។ សម្រាប់រយៈពេល១២ខែក្រោយ ឪពុកម្តាយខ្ញុំបានព្យាយាមអះអាងនូវព័ត៌មានពីស្ពាននៃអ្វីដែលបានកើតឡើង ហើយរកឃើញនូវហេតុផលដែលរដ្ឋាភិបាលNew Zealand នៅតែបានគាំទ្ររបបប៉ុល ពត។ ស្របពេលជាមួយគ្នានោះដែរ ពួកគេបានព្យាយាមរក្សានូវការធ្វើពាណិជ្ជកម្មរបស់ខ្លួន និងទប់ស្កាត់ក្ស័យធន។

២.១៦ ជីវិតគ្រួសារមានការបែកបាក់។ ក្នុងអំឡុងពេលនេះ ខ្ញុំហូបស្រាបន្ធូរអារម្មណ៍ ហើយស្រវឹងអស់ជាច្រើនយប់ ថ្វីត្បិតខ្ញុំមានអាយុត្រឹមតែ១៥ឆ្នាំក៏ដោយ។ ឪពុកម្តាយខ្ញុំបានដោះស្រាយនូវ ទុក្ខសោករបស់ខ្លួនគាត់តាមមធ្យោបាយផ្ទាល់ខ្លួន ហើយមិនបានចាប់អារម្មណ៍នូវឥរិយាបទរបស់ខ្ញុំទេ ឬពួកគាត់មានអារម្មណ៍អស់កម្លាំងក្នុងការធ្វើអ្វីមួយ។ ការពិត ខ្ញុំបាត់បង់Kerry និងឪពុកម្តាយខ្ញុំ។

២.១៧ កាលខ្ញុំនៅផ្ទះ ខ្ញុំជារឿយៗប្រកែកគ្នាជាមួយបងប្រុសទីពីររបស់ខ្ញុំឈ្មោះ John ដែលត្រូវបានគេវិនិច្ឆ័យរោគឃើញមានជំងឺផ្នែកស្មារតី។ ខ្ញុំជឿថា ការបាត់បង់បងប្អូនស្និតស្នាលរបស់គាត់ បានជះឥទ្ធិពលយ៉ាងខ្លាំងមកលើរូបគាត់។

២.១៨ ជិតរយៈពេលពីរឆ្នាំ បន្ទាប់ពីKerryត្រូវបានគេចាប់ Johnបានធ្វើអត្តឃាត ដោយលោតពីលើច្រាំងក្បែរផ្ទះគ្រួសារយើង។

២.១៩ ទាំងKerry ទាំងJohnបានស្លាប់នៅអាយុ២៨ឆ្នាំ។

២.២០ ផលប៉ះពាល់នៃការបាត់បង់ដ៏មហន្តរាយទាំងនេះមកលើគ្រួសាររបស់យើង មិនអាចវាស់ស្ទង់បានឡើយងាយៗនោះឡើយ។ វាជាការបាត់បង់ដ៏ធំធេង និងមិនអាចពន្យល់បាន។

២.២១ ខ្ញុំតែងគិតថា ប្រសិនបើជីវិតKerry មិនត្រូវបានគេផ្តាច់យកទៅនោះម្ល៉េះសមជីវិតគ្រួសារយើងមិនដឹងជាសប្បាយប៉ុណ្ណានោះទេ។ មិនអាចនិយាយបានទេ។

២.២២ ខ្ញុំក៏មានអារម្មណ៍យល់ពីទឹកចិត្តប្រជាជនកម្ពុជា ដែលបានបាត់បង់មនុស្សជាទីស្រលាញ់ដែរ។ ក្នុងករណីជាច្រើនវាគឺជាសមាជិកគ្រួសារជាច្រើន។ ខ្ញុំពិតជាមិនអាចយល់បាននូវការឈឺចាប់ ដែលពួកគេបានឆ្លងកាត់ និងសភាពកំហឹង និងសេចក្តីភ័យខ្លាចដែលមិនអាចជួយបានដែល ពួកគេត្រូវតែបានរស់នៅជាមួយ។ ខ្ញុំមានការស្រលាញ់ចំពោះពួកគេទាំងអស់។

២.២៣ ចុងបញ្ចប់ បងប្រុសខ្ញុំគឺជាមនុស្សម្នាក់អស្ចារ្យ ដែលត្រូវបាត់ខ្លួនគួរឱ្យអាណិតអាសូរ។ ខ្ញុំសូមជូនពរឱ្យគាត់មានឱកាសជួបប្រពន្ធរបស់ខ្ញុំ និងកូនរបស់ខ្ញុំ ហើយនិងគាត់។

២.២៤ មិត្តម្នាក់របស់Kerry ថ្មីៗនេះបានពិពណ៌នាអំពីរូបគាត់ឱ្យខ្ញុំស្តាប់ថា គាត់ជា "មនុស្សឆើតឆាយ សង្ហាណាស់"។

**សូមកត់សំគាល់**

សារណានេះត្រូវបានធ្វើឡើងដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន ការសិក្សាស្រាវជ្រាវដែលបានធ្វើឡើងដោយខ្លួនខ្ញុំ James Bellamy និងមជ្ឈមណ្ឌលឯកសារកម្ពុជា(DCCam)។

ព័ត៌មានក៏ត្រូវបានអ្នកដែលធ្វើការសិក្សាស្រាវជ្រាវដោយផ្ទាល់ស្វែងរកផងដែរ ដែលក្នុងនោះរួមមាន សមាជិកគ្រួសារជនរងគ្រោះដទៃទៀត និងអ្នកកាសែត។ ទំនាក់ទំនងត្រូវបានធ្វើឡើងជាមួយបណ្ដាមិត្តភ័ក្តជិតស្និទ្ធ អតីតដៃគូ សមាជិកគ្រួសារJohn Dewhurst និងStuart Glass ក្នុងប្រទេសអូស្ត្រាលី កាណាដា និងអង់គ្លេសផងដែរ។ យើងបាននិយាយជាមួយអ្នកទេសចរណ៍ ដែល បានជិះនាវា Foxy Lady ជាមួយKerry ពេលធ្វើដំណើរលើកចុងក្រោយ មុនពេលដែលJohn Dewhurst បានជិះនាវានោះ។

ប្រភពឯកសារធំបំផុតរបស់យើង រួមមានចម្លើយសារភាពទាំងឡាយមានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងការធ្វើសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហមប្រាំនាក់ក្នុងទីក្រុងភ្នំពេញ ដែលបានធ្វើការនៅឯគុកក្នុងអំឡុងឆ្នាំ១៩៧៨ ដែលមានឈ្មោះ៖ ហ៊ឹម ហ៊ុយ(Him Huy) សមមិត្ត សឿ(Seour) សមមិត្ត ពៅ(Pouv) សមមិត្ត ស៊ូទី(Suti) និងញ៉ែម អេន(Nhem En)។ អ្នកនៅសល់ពីស្លាប់ពីគុកទួលស្លែង មានឈ្មោះ វណ្ណៈ(Vannak) និងជុង ម៉ី(Chung Mey) ក៏ត្រូវបានធ្វើសម្ភាសន៍ផងដែរ។